# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២៣-១០-២០១៤ -ព្រះរាជក្រម នស/រកម/១០១៤/០២២ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ស្តីពី វិសោធនកម្មមាត្រា ៧៦ និង មាត្រាទាំងឡាយពីជំពូកទី ១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១០២៧២


### ២~ព្រះរាជក្រឹត្យ


០៩-១០-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១០១៤/១២៣៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ធាន សេង** (TIAN SHENG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តស៊ីឈ័ន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ជា សេង** (CHEA SENG) ១០២៧៨

០៩-១០-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១០១៤/១២៣៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **លូ ហួយលីង** (LU HUILING) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តគ័ងស៊ី សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **សុខ លាភ** (SOK LEAP) ១០២៧៩

១៣-១០-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១០១៤/១២៣៦ ស្តីពី ការដាក់ឯកឧត្តម **ឱម យ៉ិនទៀង** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅអង្គភាពប្រឆាំងអំពើពុករលួយ ១០២៨០

១៣-១០-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១០១៤/១២៣៧ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ០៣ រូប ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១០២៨១

១៣-១០-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១០១៤/១២៣៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ម៉ៅ សុវណ្ណា** ជាជំនួយការ ឯកឧត្តម **កែ គីមយ៉ាន** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ១០២៨៣

១៣-១០-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១០១៤/១២៣៩ ស្តីពី ការតែងតាំង ឯកឧត្តម **ជា ចាន់ទុំ** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ របស់ក្រសួងផែនការ ជំនួសលោកជំទាវ **ចំរើន កត្តិកា** ដែលត្រូវផ្ទេរចេញ ១០២៨៤

១៣-១០-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១០១៤/១២៤០ ស្តីពី ការប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ ជាករណីពិសេស ជូនមន្ត្រីរាជការ ៦៨ រូប នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១០២៨៥

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

៣១-១០-២០១៤ -អនុក្រឹត្យលេខ ២៨០ អនក្រ.បក ស្តីពី ការបង្កើតថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ១០២៩០

០៣-១១-២០១៤ -អនុក្រឹត្យលេខ ២៨១ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច កម្ពុជា-បេឡារុស ១០២៩២

១១-៨-២០១៤ -អនុក្រឹត្យលេខ ១១៧៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០២៩៦

១១-៨-២០១៤ -អនុក្រឹត្យលេខ ១១៧៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស សហមេត្រី ១០២៩៨

១១-៨-២០១៤ -អនុក្រឹត្យលេខ ១១៧៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០២៩៩

១១-៨-២០១៤ -អនុក្រឹត្យលេខ ១១៧៩ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រី នគរបាលជាតិកម្ពុជា ១០៣២៥

១១-៨-២០១៤ -អនុក្រឹត្យលេខ ១១៨០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ១០៣២៦

១២-៨-២០១៤ -អនុក្រឹត្យលេខ ១១៨១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១០៣២៧

១២-៨-២០១៤ -អនុក្រឹត្យលេខ ១១៨២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១០៣២៨

១២-៨-២០១៤ -អនុក្រឹត្យលេខ ១១៨៣ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ១០៣៣០

១២-៨-២០១៤ -អនុក្រឹត្យលេខ ១១៨៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០៣៣១

១២-៨-២០១៤ -អនុក្រឹត្យលេខ ១១៨៥ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១០៣៣២

១២-៨-២០១៤ -អនុក្រឹត្យលេខ ១១៨៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៣៣៣

១២-៨-២០១៤ -អនុក្រឹត្យលេខ ១១៨៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៣៣៧

១២-៨-២០១៤ -អនុក្រឹត្យលេខ ១១៨៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៣៣៨

១៣-៨-២០១៤ -អនុក្រឹត្យលេខ ១១៨៩ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មថ្នាក់មន្ត្រីរាជការ ១០៣៣៩

១៣-៨-២០១៤ -អនុក្រឹត្យលេខ ១១៩០ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ១០៣៤០

១៣-៨-២០១៤ -អនុក្រឹត្យលេខ ១១៩១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ១០៣៤២

១៣-៨-២០១៤ -អនុក្រឹត្យលេខ ១១៩២ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ១០៣៤៤

១៣-៨-២០១៤ -អនុក្រឹត្យលេខ ១១៩៣ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ១០៣៤៦

## ២-សេចក្តីសម្រេច

២៨-១០-២០១៤ -សេចក្តីសម្រេចលេខ ១៤៧ សសរ ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ១០៣៤៨

២៨-១០-២០១៤ -សេចក្តីសម្រេចលេខ ១៤៨ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ ១០៣៥១

៣០-១០-២០១៤ -សេចក្តីសម្រេចលេខ ១៤៩ សសរ ស្តីពី ការកំណត់តួនាទី និងភារកិច្ចរបស់ប្រធាន និងអនុប្រធានអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ១០៣៥៤

៣១-១០-២០១៤ -សេចក្តីសម្រេចលេខ ១៥០ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ១០៣៥៦

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៨-៨-២០១៤ -ប្រកាសលេខ ៩៦២ សហវ.ប្រក ស្តីពី ការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ អចលនទ្រព្យ *(ត មកពីរាជកិច្ច លេខ ៧៤-៨២)* ១០៣៥៩

០៩-១០-២០១៤ -ប្រកាសលេខ ១១៣៩ សហវ.ប្រក ស្តីពី ការចុះបញ្ជីពន្ធដារ ១០៣៩៣

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

០២-៩-២០១៤ -ប្រកាសលេខ ០២០៣ ឧស.កឧ.ប្រក.៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីលសារាំង (ខេមបូឌា) បង្កើតរោងចក្រផលិត អំបោះ ១០៣៩៩

០២-៩-២០១៤ -ប្រកាសលេខ ០២០៤ ឧស.កឧ.ប្រក.៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភើហ្វម វ៉ែលហ្វូលឌីង (ខេមបូឌា) លីមីធីត បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ១០៤០៣

២៧-១០-២០១៤ -ប្រកាសលេខ ៥៥៩ MIH/2014 ស្តីពី ឯកសណ្ឋានមន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ១០៤០៧

# ព្រះរាជក្រម

នស/រកម/១០១៤/០២២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

# ច្បាប់ធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្មមាត្រា ៧៦ និងមាត្រាទាំងឡាយពីជំពូកទី ១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រាតែមួយ.-**

មាត្រា ៧៦ និងមាត្រាទាំងឡាយពី ជំពូកទី ១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែប្រែដូចតទៅ ៖

**មាត្រា ៧៦.- ថ្មី**

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

## ជំពូកទី ១៥ ថ្មី(ពីរ)
## អំពីអង្គការរៀបចំការបោះឆ្នោត

**មាត្រា ១៥០.- ថ្មី (ពីរ)**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់

ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

មុខងារជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចធ្វើជាសមាជិកនៃគណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគមសហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ ។

**មាត្រា ១៥១.- ថ្មី(ពីរ)**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមាសភាពប្រាំបួនរូបដែលទទួលអាណត្តិប្រាំឆ្នាំ ។ សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមួយរូប ត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដំណើរការរៀបចំឲ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា រៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភាដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បាត់បង់សមាជិកភាពរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវចាត់នីតិវិធីជ្រើសរើស សមាសភាពថ្មីជំនួស ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ គិតពីថ្ងៃបាត់បង់សមាជិកភាព ។ នីតិវិធីលំអិតនៃការជ្រើសរើសសមាសភាពថ្មី ជំនួស ត្រូវកំណត់ដោយឡែកក្នុងច្បាប់ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១៦ ថ្មី (ពីរ)
## អំពីអានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

**មាត្រា ១៥២.- ថ្មី (ពីរ មាត្រា ១៥០ ថ្មី)**

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

**មាត្រា ១៥៣.- ថ្មី(ពីរ មាត្រា ១៥១ ថ្មី)**

ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១៥៤.- ថ្មី (ពីរ មាត្រា ១៥២ ថ្មី)**

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឲ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១៥៥.- ថ្មី (ពីរ មាត្រា ១៥៣ ថ្មី)**

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

## ជំពូកទី ១៧ ថ្មី
## អំពីអន្តរប្បញ្ញត្តិ

**មាត្រា ១៥៦.- ថ្មី (ពីរ មាត្រា ១៥៤ ថ្មី)**

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឲ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៥៧.- ថ្មី (ពីរ មាត្រា ១៥៥ ថ្មី)**

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និង អនុប្រធានទីពីរ នៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ ក្នុងប្រទេសទាមទារ ។

**មាត្រា ១៥៨.- ថ្មី(ពីរ មាត្រា ១៥៦ ថ្មី)**

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមាន ចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ ។

**មាត្រា ១៥៩.- ថ្មី (ពីរ មាត្រា ១៥៧ ថ្មី)**

នីតិកាលទី ១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភា ថ្មីចូលកាន់តំណែង ។

សម្រាប់នីតិកាលទី ១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។

-ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា ។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាម សំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិក នៃគណបក្សដែលមាន អាសនៈនៅក្នុងរដ្ឋសភា ។

-កិច្ចប្រជុំជាសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

**មាត្រា ១៦០.– ថ្មី (ពីរ មាត្រា ១៥៨ ថ្មី)**

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៤

នស.១៤១០.១៣០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ:១៣៦៥ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៤/១៧៣៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ធាន សេង** (TIAN SHENG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៦៨ នៅខេត្តស៊ីឈ័ន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ជា សេង** (CHEA SENG)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ស. ១៤ ១០. ១២៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤

លេខ: ១៧៤០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ១១ ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៤/១៧៣៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **លូ ហួយលីង** (LU HUILING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៧៨ នៅខេត្តគ័ងស៊ី សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **សុខ លាភ** (SOK LEAP) ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៦៧.១៤១០.០២៥៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤

លេខ:១៧៤១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ១០ ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៤/១២៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់ ឯកឧត្តម **ឱម យ៉ិនទៀង** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅអង្គភាពប្រឆាំងអំពើពុករលួយ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរក.១៤១០.១២៥៧

លេខៈ ១២៧៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១១ ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១៤/១២៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ០៣ រូប ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាៈ

តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៤ ៖

១- លោកស្រី អ៊ុយ សាវជី មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL — ព្រះបរមរាជវាំង

- តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៤ ។

២- លោកស្រី **ឆេត សុខបញ្ញា** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤

- តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៤ ។

៣- លោក **កែច ចិន្តា** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៣

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៣៧.១៤១០.១២៥៨

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* **១៣** *ខែ តុលា ឆ្នាំ ២០១៤*

លេខ:១២៧៨ ស.ណ

**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ តុ៣ ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៤/១២៣៨

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រត្ថខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង និងផ្ដល់ឋានៈ ឯកឧត្តម **ម៉ៅ សុខណ្ណា** ជាជំនួយការ ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រ៧. ១៤១០. ១២៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤

លេខ:១២៦៧ ស.ណ
**សំណៅចម្លងមានគុណប្រយោជន៍ចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៤/[illegible]

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **ជា ចាន់ទុំ** ជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ របស់ក្រសួងផែនការ ជំនួសលោកជំទាវ **ចំរើន គន្ធិកា** ដែលត្រូវផ្ទេរចេញ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤*

លេខ: [illegible] ស.ណ
**សំណៅដែលមានតម្លៃជាការចេញផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១៤/១២៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌជាករណីពិសេស ជូនមន្ត្រីរាជការ ៣៨ រូប មកឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖

១- លោកស្រី **ហាង់ ស៊ីមួរីន** ពីក្រមការ ថ្នាក់លេខ ១២ មកអនុមន្ត្រី ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★ រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

| | | |
|---|---|---|
| ២- លោកស្រី **លឹម ឈុនលី** | ពីក្រមការ ថ្នាក់លេខ ១៤ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣- លោក **លឹម ស៊ីឡេង** | ពីក្រមការ ថ្នាក់លេខ ១៣ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៤- លោក **ម៉េន លុច** | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៥- លោក **ពត សុខា** | ពីក្រមការ ថ្នាក់លេខ ៤ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៦- លោក **សៀង សាមៀន** | ពីក្រមការ ថ្នាក់លេខ ១៣ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៧- លោក **គុយ សេរិនធី** | ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ២ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៨- លោកស្រី **ម៉ែន ណារិន** | ពីក្រមការ ថ្នាក់លេខ ៧ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៩- លោក **ញ៉ូង មនុញ្ញ** | ពីក្រមការ ថ្នាក់លេខ ១២ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០- លោក **សុភ ភាណោត** | ពីក្រមការ ថ្នាក់លេខ ១៣ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១១- លោក **ហ៊ុយ ម៉ាថារ៉ូ** | ពីក្រមការ ថ្នាក់លេខ ១៣ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១២- លោកស្រី **ជុំ ចាន់ធូ** | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១០ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១៣- លោក **ស៊ុន ស៊ីថា** | ពីក្រមការ ថ្នាក់លេខ ១៤ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១៤- លោកស្រី **ឌិន រម្មនា** | ពីក្រមការដើមខ្សែ ថ្នាក់លេខ ២ | មកអនុមន្ត្រី ថ្នាក់លេខ ៨ |
| ១៥- លោក **ម៉ាន់ ម៉ិនឈឿន** | ពីក្រមការដើមខ្សែ ថ្នាក់លេខ ៨ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១៦- លោក **ហៀង សុខហួត** | ពីនាយក្រមការ ថ្នាក់លេខ ៣ | មកអនុមន្ត្រី ថ្នាក់លេខ ៦ |
| ១៧- លោកស្រី **ម៉ឹង សុវណ្ណារី** | ពីក្រមការដើមខ្សែ ថ្នាក់លេខ ៣ | មកអនុមន្ត្រី ថ្នាក់លេខ ៩ |
| ១៨- លោកស្រី **ខៀវ សៅវុត្ថា** | ពីនាយក្រមការ ថ្នាក់លេខ ៣ | មកអនុមន្ត្រី ថ្នាក់លេខ ៦ |
| ១៩- លោក **ឈុន ហេង** | ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ៨ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២០- លោក **លី សារឿន** | ពីក្រមការ ថ្នាក់លេខ ១៤ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២១- លោក **អន ស៊ីនួន** | ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ១១ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២២- លោក **សែ សុយន** | ពីក្រមការ ថ្នាក់លេខ ១៤ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៣- លោក **គឹម ឌួន** | ពីក្រមការ ថ្នាក់លេខ ៨ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៤- លោក **ឃុន វ៉ាន់** | ពីក្រមការដើមខ្សែ ថ្នាក់លេខ ៤ | មកអនុមន្ត្រី ថ្នាក់លេខ ១០ |
| ២៥- លោក **ស៊ុភ គឹមហេន** | ពីនាយក្រមការ ថ្នាក់លេខ ៤ | មកអនុមន្ត្រី ថ្នាក់លេខ ៧ |
| ២៦- លោក **ហ៊ាល ទូច** | ពីនាយក្រមការ ថ្នាក់លេខ ៤ | មកអនុមន្ត្រី ថ្នាក់លេខ ៧ |
| ២៧- លោក **ឈឹម ម៉េងហុង** | ពីក្រមការ ថ្នាក់លេខ ៨ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៨- លោក **គឹម និមិត្រ** | ពីក្រមការ ថ្នាក់លេខ ៨ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៩- លោក **យិន ចិន្តាមុន្នី** | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣០- លោក **ហៀង ស្រ៊ុន** | ពីក្រមការ ថ្នាក់លេខ ១៤ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣១- លោក **នុត មន្ថា** | ពីក្រមការ ថ្នាក់លេខ ១៤ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |

| | | |
|---|---|---|
| ៣២- លោក **ឥន្ទ ទឹម** | ពីក្រមការ ថ្នាក់លេខ ៦ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣៣- លោក **អៀង ឡូន** | ពីក្រមការ ថ្នាក់លេខ ៣ | មកអនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៣៤- លោក **ឈឹម ទេវចន់** | ពីក្រមការ ថ្នាក់លេខ ៤ | មកអនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣៥- លោក **ឡូន សុគន្ធ** | ពីនាយក្រមការ ថ្នាក់លេខ ១ | មកអនុមន្ត្រី ថ្នាក់លេខ ៣ |
| ៣៦- លោក **រឿង ផៃរិទ្ធិ** | ពីនាយក្រមការ ថ្នាក់លេខ ១ | មកអនុមន្ត្រី ថ្នាក់លេខ ៣ |
| ៣៧- លោក **ស៊ិន ថុង** | ពីនាយក្រមការ ថ្នាក់លេខ ១ | មកអនុមន្ត្រី ថ្នាក់លេខ ៣ |
| ៣៨- លោក **រស់ ផល្លា** | ពីនាយក្រមការ ថ្នាក់លេខ ៦ | មកអនុមន្ត្រី ថ្នាក់លេខ ១១ |

**មាត្រា ២ :** ប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌជាករណីពិសេស ជូនមន្ត្រីរាជការ ៣០ រូប មកឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖

| | |
|---|---|
| ១- លោកស្រី **ចោង ច័ន្ទជាទី** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ ៣<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៦ |
| ២- លោក **គ្រឿង ប្រុណាភិត** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ ៤<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៧ |
| ៣- លោក **ផន ផុន** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៦<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៣ |
| ៤- លោក **ម៉ៅ ដួប** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ១<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨ |
| ៥- លោក **សូ សំ** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ៧<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៦- លោកស្រី **ស៊ុត សុគន្ធនារី** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ ៤<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៧ |
| ៧- លោកស្រី **ឯក សាពានី** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ ៣<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៦ |
| ៨- លោក **ប៉ក់ សុភាព** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១២<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៩- លោកស្រី **គង់ សាម៉ុន** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៦<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៣ |

| | |
|---|---|
| ១០- លោក **ម៉ុត ម៉ីន** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ ៥<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៩ |
| ១១- លោក **ពេជ្រ តៅ** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៥<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ១២- លោក **សុខ ចែត** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១២<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ១៣- លោក **និត្យ មិត្ត** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១២ |
| ១៤- លោក **គង់ សាផន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ១៥- លោក **ហ៊ឹម ហ៊ីន** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១០<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ១៦- លោក **ម៉ាន់ សេរី** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៥<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១១ |
| ១៧- លោក **អ៊ឹម តិចម៉ែង** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៦<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ១៨- លោក **អុច ខោរ៉ាមិច** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៥<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ១៩- លោក **លាង ម៉ុង** | ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១១<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ២០- លោក **ហោ ឧត្តរី** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ១<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨ |
| ២១- លោក **សោម ឡុងឌី** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨ |
| ២២- លោក **អាង អរុណ** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ២<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៣ |
| ២៣- លោក **ទឹម ទេពតារា** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨ |
| ២៤- លោក **ទូច សុទ្ធី** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៣<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៣ |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | |
|---|---|
| ២៥- លោក **ហ៊ឹម ឡូញ** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ២ |
| | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨ |
| ២៦- លោក **អ៊ុំ សាខុម** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ ១ |
| | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២៨- លោក **ជ័យ ទិមានរិទ្ធ** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៩ |
| | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ២៧- លោក **ផេង ឧត្តី** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ ២ |
| | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២៩- លោក **សុខ សុយ៉ុន** | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ ៦ |
| | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១១ |
| ៣០- លោកស្រី **ចាន់ ម៉ាន់នី** | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៣ |
| | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |

**មាត្រា ៣ ៈ** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៤១០.១៤៦១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ១៣ *ខែ តុលា ឆ្នាំ ២០១៤*

លេខៈ១២៧៧ ស.ណ
**សំណៅចំលងចេញពីច្បាប់ដើម សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧៩០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមសំណូមពររបស់សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា ១ :** បង្កើតថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ដែលជាអង្គការកំពូលសម្រាប់ជំនុំជម្រះដោះស្រាយអធិករណ៍ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-សម្តេចព្រះពុទ្ធាចារ្យ | **ទួច សុខទោហោរ** | ប្រធាន |
| ២-ព្រះមហារាជធម្ម | **ចន្ទ្រ សារេតា** | អនុប្រធានទី១ |
| ៣-ព្រះមហាព្រហ្មមុនី | **គឹម សុផា** | អនុប្រធានទី២ |
| ៤-ព្រះអរិយវង្ស | **គង់ ច័ន្ទថុល** | សមាជិក |
| ៥-ព្រះធម្មវរោត្តម | **ទួច សាធរ** | សមាជិក |
| ៦-ព្រះវជិរមេធា | **លឿន ហាមុនី** | សមាជិក |
| ៧-ព្រះគ្រូមង្គលមុនី | **ឈិន ហាន** | សមាជិក |
| ៨-ព្រះគ្រូធម្មរាជចរិយា | **ខួន ស្ដេចតគ្គី** | លេខាធិការ |
| ៩-ព្រះគ្រូទីបញ្ញាណមុនី | **ខេន ស៊ាខលី** | លេខាធិការរង ។ |

**មាត្រា ២ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ មានភារកិច្ចដូចខាងក្រោម៖

- ជាសហធម្មិកសង្ឃជាន់ខ្ពស់របស់សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃជំនុំជម្រះ និងដោះស្រាយរម្ងាប់អធិករណ៍ដែលកើតមានឡើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ជំនុំជម្រះអធិករណ៍ដែលកើតមានឡើងរវាងសង្ឃនិងសង្ឃ រវាងសង្ឃនិងគ្រហស្ថ ដែលវិន័យធរ ធម្មធរ អនុគណ មេគណ គណៈសង្ឃនៃគណៈធម្មយុត្តិកនិកាយ មិនអាចរម្ងាប់បាន ។

- ចាត់តាំងតំណាងចុះទៅស្រាវជ្រាវ ឈ្វេងយល់រកហេតុផលពិតប្រាកដអំពីប្រភពទំនាស់អំពីយន្តការដោះស្រាយកន្លងមកធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន ។
- រកគ្រប់វិធី ធ្វើការណែនាំ សម្របសម្រួលនូវភាគីបង្កអធិករណ៍ឲ្យយល់គ្នាដោយប្រើប្រាស់គ្រប់រូបភាពសិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល ។
- ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ទើបធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឲ្យភាគីនីមួយៗអាចទទួលយកបានដោយគ្មានការវង្វៀស ។
- ត្រូវមានតម្លាភាពក្នុងការរម្ងាប់អធិករណ៍នីមួយៗ ដោយឈរលើទស្សនៈគ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាចអគតិធម៌ទាំង៤ ។
- ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ ឬក្រសួងធម្មការ និងសាសនា ប្រគល់ឲ្យពិនិត្យដោះស្រាយ ។
- ក្នុងការដោះស្រាយអធិករណ៍ត្រូវមានតំណាងមន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅនឹងកន្លែងអធិករណ៍ ចូលរួមជាអ្នកពិគ្រោះយោបល់ និងអង្កេតការណ៍ក្នុងការដោះស្រាយរម្ងាប់អធិករណ៍នោះ ។
- ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ត្រូវធ្វើរបាយការណ៍អំពីករណីអធិករណ៍ និងករណីបានជំនុំជម្រះដោះស្រាយអធិករណ៍នីមួយៗ បញ្ជូនមកសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ និងក្រសួងធម្មការ និងសាសនា ដើម្បីមានមុខការបន្ត ។

**មាត្រា ៣ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ត្រូវរៀបចំលេខាធិការដ្ឋានមួយដឹកនាំដោយព្រះប្រធាន ០១ រូប និងមានសមាជិកមួយចំនួនជាជំនួយការ តាមការចាំបាច់ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា ។

**មាត្រា ៤ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែកសម្រាប់ដំណើរការ ។

**មាត្រា ៥ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ គ្រប់រាជធានី ខេត្ត និងសមាសភាពដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ៧ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

**មិន ឃិន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៦៩១..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច កម្ពុជា-បេឡារុស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីប្រកាសរួមរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋបេឡារុស ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ នៅទីក្រុងមីនស្ក សាធារណរដ្ឋបេឡារុស
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច កម្ពុជា-បេឡារុស ក្នុងគោលបំណងសម្របសម្រួល និងធានាប្រសិទ្ធភាពនៃការអនុវត្តសេចក្តីប្រកាសរួម និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស។

## ជំពូកទី២
## សមាសភាព

**មាត្រា២ .-**

គណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច កម្ពុជា-បេឡារុស មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. | ឯកឧត្តម | **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម | **ស៊ា កុសល** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤. | ឯកឧត្តម | **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. | ឯកឧត្តម | **ហ៊ូ តាំងអេង** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៦. | ឯកឧត្តម | **សាត សាមី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៧. | ឯកឧត្តម | **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. | ឯកឧត្តម | **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៩. | ឯកឧត្តម | **កាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១០. | ឯកឧត្តម | **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១១. | ឯកឧត្តម | **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២. | ឯកឧត្តម | **ជា ឧុទ្ធី** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៣. | លោកជំទាវ | **អ៊ុក ម៉ាលី** | អគ្គទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ១៤. | លោកជំទាវ | **ប៉ែន មុន្នីមករា** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិកា |
| ១៥. | លោក | **ជា សុជាតិ** | ប្រធាននាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក នៃក្រសួងពាណិជ្ជកម្ម | លេខាធិការ។ |

សមាជិកគណៈកម្មាធិការជាតិនេះ អាចត្រូវបានស្នើសុំបន្ថែមដោយប្រធានគណៈកម្មាធិការជាតិ ទៅតាមការចាំបាច់។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា៣ .-**

គណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច កម្ពុជា-បេឡារុស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការសកម្មភាព និងយុទ្ធសាស្ត្រ សម្រាប់ជំរុញនិងគាំទ្រដល់ការពង្រីកកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់វិស័យពាណិជ្ជកម្មនិងសេដ្ឋកិច្ចទ្វេភាគី និងត្រូវធានាឱ្យគោលនយោបាយនិងកម្មវិធីទាំងឡាយ ស្របគ្នាជាមួយនឹងផែនការអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។
- កំណត់នូវវិស័យសក្តានុពលនិងអាទិភាព សម្រាប់កិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ រវាងប្រទេសទាំងពីរ លើពាណិជ្ជកម្មទំនិញ សេវាកម្ម វិនិយោគ និងវិស័យដទៃទៀត ដោយកំណត់ឱ្យបាននូវឱកាស បញ្ហាប្រឈម និងរបាំងចំពោះការអភិវឌ្ឍពាណិជ្ជកម្មនិងសេដ្ឋកិច្ច។
- ចូលរួមចរចា និងប្រជុំពិភាក្សាការងារជាមួយសមភាគីលើការងារទាក់ទងនឹងពាណិជ្ជកម្មនិងសេដ្ឋកិច្ច។

- ធ្វើសហប្រតិបត្តិការនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន វិស័យឯកជន និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីធានានូវប្រសិទ្ធភាព និងពង្រឹងនូវសង្គតិភាព និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-បេឡារុស។
- សិក្សា-រៀបចំលើកគម្រោង និងកម្មវិធី ដែលត្រូវអភិវឌ្ឍដោយឡែក និងអភិវឌ្ឍរួម ដោយធ្វើការសម្របសម្រួលផ្ទៃក្នុង និងជាមួយបណ្តាប្រទេសផ្តល់ជំនួយ សំដៅរកថវិកាអនុវត្តគម្រោង។
- ធ្វើការទាក់ទាញ និងលើកទឹកចិត្តវិនិយោគិន ដើម្បីឱ្យមានការបណ្តាក់ទុននៅកម្ពុជា។
- ជំរុញការអនុវត្តសេចក្តីប្រកាសរួម និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធរវាងកម្ពុជា-បេឡារុស ព្រមទាំងពិនិត្យនិងលើកសំណើកែសម្រួល ឬធ្វើវិសោធនកម្មក្នុងករណីចាំបាច់។
- វាយតម្លៃលើការអនុវត្ត និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពសកម្មភាពអនុវត្តការងារ និងលទ្ធផលការងារ ព្រមទាំងផ្តល់អនុសាសន៍តាមការចាំបាច់ជូនរាជរដ្ឋាភិបាល។
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។
- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៤ .-**

សមាជិកគណៈកម្មាធិការជាតិត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មាធិការជាតិ ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធាន ឬតំណាង ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

## ជំពូកទី៤
## ការប្រព្រឹត្តទៅ

**មាត្រា៥ .-**

គណៈកម្មាធិការជាតិអាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន អ្នកជំនាញការជាតិ និងអន្តរជាតិ ឬភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ដើម្បីកែលម្អ និងធ្វើឱ្យកិច្ចសហប្រតិបត្តិការកាន់តែមានប្រសិទ្ធភាព។

**មាត្រា៦ .-**

ប្រធានគណៈកម្មាធិការជាតិមានសិទ្ធិបង្កើតអនុគណៈកម្មាធិការ ក្រុមការងារ និងក្រុមពិគ្រោះយោបល់ តាមការចាំបាច់ ដើម្បីជួយបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

សមាសភាព និងតួនាទីភារកិច្ចរបស់អនុគណៈកម្មាធិការ ក្រុមការងារ និងក្រុមពិគ្រោះយោបល់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិ។

**មាត្រា៧ .-**

គណៈកម្មាធិការជាតិមានលេខាធិការដ្ឋានមួយ ជាសេនាធិការ ស្ថិតនៅនាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក នៃក្រសួងពាណិជ្ជកម្ម។

លេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិ ត្រូវដឹកនាំដោយប្រធានលេខាធិការដ្ឋាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិ ត្រូវកំណត់ដោយប្រកាសរបស់ប្រធានគណៈកម្មាធិការជាតិ។

**មាត្រា៨ .-**

គណៈកម្មាធិការជាតិមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីបំពេញការងាររបស់ខ្លួន។៚

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: [illegible] អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ២៥គ្រឿង ជូននាយទាហាន និងនាយទាហានរង ចំនួន ២៥រូប ចំណុះតំបន់ប្រតិបត្តិការសឹករងកំពង់ស្ពឺ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ត្រី | ស៊ិន | ទិសិដ្ឋ | អត្តលេខ ០២៨៩៦៩ នាយរងការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងកំពង់ស្ពឺ |
| ២- | វរសេនីយ៍ត្រី | អ៊ុន | សារី | អត្តលេខ ០២៨៩៨០ នាយរងការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងកំពង់ស្ពឺ |
| ៣- | វរសេនីយ៍ត្រី | ម៉ា | សំអុល | អត្តលេខ ១៤០៥៣២ នាយរងការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករងកំពង់ស្ពឺ |
| ៤- | អនុសេនីយ៍ឯក | ពៅ | នូ | អត្តលេខ ១៥៧៥៩២ មេបញ្ជាការ ផ្នែកសឹករងឱរ៉ាល់ |
| ៥- | អនុសេនីយ៍ឯក | ឈួន | គីមសុខ | អត្តលេខ ១៤០៤២២ មេបញ្ជាការរង ផ្នែកសឹករងភ្នំស្រួច |
| ៦- | អនុសេនីយ៍ឯក | ម៉ែន | ដារ៉ា | អត្តលេខ ១៥៧៣៤១ មេបញ្ជាការរង វរសេនាតូចលេខ១ |
| ៧- | អនុសេនីយ៍ឯក | ឡាយ | បូរិន | អត្តលេខ ០៤១៣៩១ មេបញ្ជាការ អនុសេនាធំទី៣ វរសេនាតូចលេខ១ |
| ៨- | អនុសេនីយ៍ឯក | សន | ម៉េង | អត្តលេខ ១៥៧៣៦៥ មេបញ្ជាការរង ផ្នែកសឹករងគងពិសី |
| ៩- | អនុសេនីយ៍ឯក | ហាឡុ | ស៊ីថុល | អត្តលេខ ១៣៤៥១៣ មេបញ្ជាការរង ផ្នែកសឹករងបសេដ្ឋ |
| ១០- | អនុសេនីយ៍ឯក | សុខ | ផន | អត្តលេខ ១៥៧៣៤០ មេបញ្ជាការរង ផ្នែកសឹករងបសេដ្ឋ |
| ១១- | អនុសេនីយ៍ឯក | ឌី | សុឃន | អត្តលេខ ១៥៧២៧២ ជំនួយការហិរញ្ញវត្ថុ វរសេនាតូចលេខ២ |
| ១២- | អនុសេនីយ៍ឯក | អ៊ួន | សារ៉ាន | អត្តលេខ ០២៨០០៨ មេបញ្ជាការ អនុសេនាធំទី១ វរសេនាតូចលេខ២ |
| ១៣- | អនុសេនីយ៍ឯក | យ៉េម | ឆាយ៉ា | អត្តលេខ ១៥៧៣០៩ នាយការិយាល័យបច្ចេកទេស តំបន់ប្រតិបត្តិការសឹករងកំពង់ស្ពឺ |

| | | | | |
|---|---|---|---|---|
| ១៤- | អនុសេនីយ៍ឯក | គ្រួច | សាមិត្ត | អត្តលេខ ១៥៧៣៦០ មេបញ្ជាការ ផ្នែកសឹករងសំរោងទង |
| ១៥- | អនុសេនីយ៍ឯក | មាស | សម្បត្តិ | អត្តលេខ ១៥៧៣៨៩ មេបញ្ជាការរង ផ្នែកសឹករងច្បារមន |
| ១៦- | អនុសេនីយ៍ត្រី | ម៉ៅ | មន | អត្តលេខ ១៣៤៧១៧ មេបញ្ជាការរង ផ្នែកសឹករងច្បារមន |
| ១៧- | អនុសេនីយ៍ត្រី | ផៃ | ផេន | អត្តលេខ ១៣៤៥៤៦ បញ្ជាការរង អនុសេនាធំ វរសេនាតូចលេខ២ |
| ១៨- | អនុសេនីយ៍ត្រី | ម៉ើ | ចន្ថា | អត្តលេខ ១៨៦៦១០ មេបញ្ជាការរង វរសេនាតូចលេខ២ |

ខ-មេដាយប្រាក់ការងារ

| | | | | |
|---|---|---|---|---|
| ១- | អនុសេនីយ៍ទោ | ឌុំ | សំអុល | អត្តលេខ ០៤១៣៩៦ មេបញ្ជាការ អនុសេនាធំទី១ វរសេនាតូចលេខ១ |
| ២- | អនុសេនីយ៍ត្រី | ស្ងួន | សេម | អត្តលេខ ១៥៧៣៣៥ មេបញ្ជាការរង ផ្នែកសឹករងថ្លុង |
| ៣- | នាយចំណោង់ | ឌីម | រ៉ន | អត្តលេខ ១៣៤៤៦៤ ជំនួយការ ផ្នែកសឹករងថ្លុង |
| ៤- | អនុសេនីយ៍ទោ | សោម | ចណ្ណា | អត្តលេខ ១៣៤៥៥០ ជំនួយការ ផ្នែកសឹករងបសេដ្ឋ |
| ៥- | ព្រិន្ទបាលឯក | ស្ងួន | ឆារ៉ា | អត្តលេខ ១៤០៥៣៨ មេក្រុម វរសេនាតូចលេខ១ |
| ៦- | ព្រិន្ទបាលឯក | ឃឹម | រិទ្ធី | អត្តលេខ ១៣៤៦៣៩ មេរង អនុសេនាតូច វរសេនាតូចលេខ១ |
| ៧- | ព្រិន្ទបាលឯក | សៅ | សុផាណា | អត្តលេខ ១៨៦៥៥៩ មេបញ្ជាការរង អនុសេនាធំទី២ វរសេនាតូចលេខ១ |

មាត្រា ២.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣៧ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពីការជូនគ្រឿងឥស្សរិយយស សហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយស សហមេត្រីថ្នាក់ធិបឌិន្ទ** ផ្ដល់ជូនបុគ្គលិកក្រុមហ៊ុន LIN WEN CHIH SUN BOW ENTERPRISES Co.CTD ចំនួន ០២រូប ដែលបានបណ្ដាក់ទុនវិនិយោគធ្វើរោងចក្រស្បែកជើង និងបានជួយឧបត្ថម្ភសំភារៈការិយាល័យមួយចំនួនដល់រដ្ឋបាលស្រុក ស្ថិតនៅក្នុងស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលមានរាយនាមដូចខាងក្រោម :

១-លោក **ហួន លីមីង** (HUON LIMING) ជំនួយការពិសេសអគ្គនាយក

២-លោក **ទន់ ឆៃលីម** (TOUN CHHAY LIM) ជំនួយការអគ្គនាយក

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខ. ភូមិពោធិ៍ ភូមិទួលមានគុណ ភូមិក្រាំងស្វាយ ភូមិពាយនាយ ភូមិសុណនថៃ ភូមិព្រីង ភូមិគោកសំពៅ និងភូមិស្រះកែវ

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៥- ឃុំរាធរ មាន ០៥ភូមិ គឺ ÷ ភូមិតាម៉ៅ ភូមិតាហ៊ោល-ក ភូមិតាហ៊ោល-ខ ភូមិឈ្នះជ័យលើ និងភូមិឈ្នះជ័យក្រោម

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៦- ឃុំបឹងដោល មាន ១១ភូមិ គឺ ÷ ភូមិសំបួរ ភូមិតាអួក ភូមិស្វាយ ភូមិបឹងដោល ភូមិប៉ាក់ព្រី ភូមិក្លែងគង់ ភូមិអំពិល ភូមិទឹកសិន ភូមិថ្កោល ភូមិតាហៀវ និងភូមិរកាកូនសាត់

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៧- ឃុំអង្គរាជ្យ មាន ១៧ភូមិ គឺ ÷ ភូមិជ្រៃ ភូមិក្រូច ភូមិលីង្គ ភូមិពញាលៀង ភូមិធំ ភូមិព្រៃអាស្នាំង ភូមិទឹកជួរ ភូមិចំការតាម៉ូយ ភូមិឧកញ៉ាឯម ភូមិព្រៃស្រម៉ោច ភូមិស្វាយ ភូមិហារ ភូមិព្រៃវិចាន់ ភូមិស្វាយចារ ភូមិព្រៃមាស ភូមិក្រសាំងទង និងភូមិបឹងឥដ្ឋ

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៨- ឃុំជែកំពក មាន ១២ភូមិ គឺ ÷ ភូមិក្តីស្កា ភូមិពោធិ៍ ភូមិប្រថ្ម ភូមិជែកំពត ភូមិស្នោរ ភូមិត្រស់ ភូមិស្វាយទោល ភូមិអង្គស្វាយទូ ភូមិតាពូង ភូមិកំពង់ប្រាស្រី ភូមិទួលលាន និងភូមិព្រៃប្រាស្រី

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៩- ឃុំព្រះស្តេច មាន ១៣ភូមិ គឺ ÷ ភូមិអន្លង់ចារ ភូមិអំពិល ភូមិអន្ទ្រោក ភូមិទួលជៃ ភូមិតាកេត ភូមិត្នោតទោល ភូមិឫស្សីទទឹង ភូមិផ្លាំង ភូមិព្រៃទ័ព ភូមិឫស្សីទន្លេ ភូមិព្រៃរុន ភូមិផុត និងភូមិកងនាង

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១០- ឃុំសេនារាជឧត្តម មាន ១៨ភូមិ គឺ ÷ ភូមិស្វាយព្រៀម ភូមិផ្ទង់ ភូមិព្រីង ភូមិស្ពានដៃ ភូមិអំពិល ភូមិកំរោល ភូមិប្រស្នាធំ ភូមិប្រស្នាតូច ភូមិសំនយ ភូមិគំរាង ភូមិខ្លាខាំ ភូមិត្រពាំងប្រុស ភូមិជៃរាខោល ភូមិស្នោរ ភូមិទ្រា ភូមិក្រសាំងចារ ភូមិក្តាមពុក និងភូមិក្លែងគង់

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១១- ឃុំបន្ទាយចក្រី មាន ២០ភូមិ គឺ ÷ ភូមិរកាជួរទី១ ភូមិរកាជួរទី២ ភូមិរកាជួរទី៣ ភូមិពោធិ៍រំយំ ភូមិម្រេញ ភូមិជៃតា ភូមិកគោ ភូមិឯកងក ភូមិប្រោះស្វា ភូមិអំពិល ភូមិដីវីស្លាប់ ភូមិសំពោង ភូមិពោធិ៍ជ្រែក ភូមិតាអឹម ភូមិបឹងកំពត ភូមិប្របុសរលួយ ភូមិមុន្នីសិលា ភូមិពីងពង់ ភូមិឫស្សីជុក និងភូមិពោធិ៍

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

## ស្រុកពាមជរ

អចលនទ្រព្យទាំងឡាយដែលស្ថិតនៅស្រុកពាមជរ ត្រូវកំណត់តម្លៃសំណង់ និងដី ក្នុងមួយម៉ែត្រក្រឡា ដូចខាងក្រោម ÷

**ក- សំណង់ ÷** *(ឯកតាគិត ÷ ជាដុល្លារ)*

| ប្រភេទសំណង់ | ដល់ ១០ឆ្នាំ (តម្លៃ/១ម$^2$) | | | លើស ១០ឆ្នាំ (តម្លៃ/១ម$^2$) | | |
|---|---|---|---|---|---|---|
| | សំណង់ ឥដ្ឋបេតុង | សំណង់មិនមែន ឥដ្ឋបេតុង | ខុនដូ | សំណង់ ឥដ្ឋបេតុង | សំណង់មិនមែន ឥដ្ឋបេតុង | ខុនដូ |
| ជាន់ក្រោមដី | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៥០ | ១៥០ |
| ជាន់ផ្ទាល់ដី | ១៨០ | ៨០ | ៥០០ | ១៧០ | ៧០ | ៤០០ |
| ជាន់ទី១ | ១៦០ | ៧០ | ៥០០ | ១១០ | ៦០ | ៤០០ |
| ជាន់ទី២ - ទី៥ | ១៣០ | ៦០ | ៥០០ | ៨០ | ៥០ | ៤០០ |
| ជាន់ទី៦ - ទី១០ | ៥៥០ | ៥៥០ | ៥៥០ | ៤៥០ | ៤៥០ | ៤៥០ |
| ចាប់ពីជាន់ទី១១ ឡើងទៅ | ៦៥០ | ៦៥០ | ៦៥០ | ៥៥០ | ៥៥០ | ៥៥០ |

**ខ- ដី ÷**

**<u>ប្រភេទមួយ</u>** ÷ តម្លៃ ២៥ដុល្លារ ក្នុង១ម៉ែត្រក្រឡា ÷ ដីស្ថិតនៅទីប្រជុំជន

- ក្នុងទីប្រជុំជនផ្សារពាមជរ (សាលាស្រុក)
- ក្នុងទីប្រជុំជនផ្សារតាហ៊ុយ

**<u>ប្រភេទពីរ</u>** ÷ តម្លៃ ៥ដុល្លារ ដីលំនៅដ្ឋាន/១ដុល្លារ ដីស្រែ-ចំការ ក្នុង១ម៉ែត្រក្រឡា ÷ ដីស្ថិតនៅផ្លូវមេ

- សងខាងកំណាត់ផ្លូវមាត់ទន្លេ ចាប់ពីព្រំប្រទល់ស្រុកពាមរក៍ ដល់ព្រំដែនវៀតណាម (លើកលែងកំណាត់ផ្លូវដែលមានចែងក្នុងប្រភេទមួយ)

**<u>ប្រភេទបី</u>** ÷ ដីក្រៅពីការកំណត់ក្នុងប្រភេទខាងលើ (ដីលំនៅដ្ឋាន/ដីស្រែ-ចំការ)

១- ឃុំព្រែកក្របៅ មាន ០៣ភូមិ គឺ ÷ ភូមិឧត្តម ភូមិឧត្តុង្គ និងភូមិព្រែកក្របៅ

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

២- ឃុំព្រែកសំបួរ មាន ០៣ភូមិ គឺ ÷ ភូមិខ្ពប ភូមិសំបួរ និងភូមិព្រែកជ្រៅ

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៣- ឃុំកោះរកា មាន ០៤ភូមិ គឺ ÷ ភូមិស្វាយជ្រុំ ភូមិដីស្រុត ភូមិជ្រៃថ្មី និងភូមិកោះរកា

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៤- ឃុំអង្គរអេង្គ មាន ០៤ភូមិ គឺ ÷ ភូមិវាលរបងលើ ភូមិវាលរបងក្រោម ភូមិព្រៃត្រែង និងភូមិអង្គរអេង្គ

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៥- ឃុំកំពង់ប្រាសាទ មាន ០៥ភូមិ គឺ ÷ ភូមិតាហ៊ុយ ភូមិតាប៉ើ ភូមិក្រាំងក្រូច ភូមិកំពង់ប្រាសាទ និងភូមិទឹកវិល

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៦- ឃុំក្រាំងតាយ៉ង មាន ០៨ភូមិ គឺ ÷ ភូមិក្រាំងតាយ៉ង ភូមិជ្រៃឧត្តម ភូមិក្រាំងចិន ភូមិក្រាំងព្រៃផ្តៅ ភូមិព្រីង ភូមិរកាដុះ ភូមិក្រាំងស្លូរ និងភូមិពងទឹក

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៧- ឃុំឫស្សីស្រុក មាន ១១ភូមិ គឺ ÷ ភូមិឈើទាល ភូមិឥដ្ឋ ភូមិពែន ភូមិតាសូ ភូមិតាពួង ភូមិឫស្សីស្រុក ភូមិស្វាយចេក ភូមិក្រាំងពោន ភូមិពោធិខ្ពស់ ភូមិព្រៃមាន់ និងភូមិបឹងអក្សរ

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៨- ឃុំកោះសំពៅ មាន ០៥ភូមិ គឺ ÷ ភូមិពោធិថ្មី ភូមិស្វាយអណ្តូង ភូមិអំពៅព្រៃ ភូមិទួលសាំង និងភូមិខ្សាច់

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៩- ឃុំស្វាយភ្លោះ មាន ០៣ភូមិ គឺ ÷ ភូមិសង្គ្រោះ ភូមិសាមគ្គី និងភូមិបង្កែក

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

១០- ឃុំកោះចេក មាន ០៤ភូមិ គឺ ÷ ភូមិមានជ័យ ភូមិកោះចេក ភូមិស្ពាន និងភូមិកោះពាមរាំង

- តម្លៃ 0,៦0/0,៣0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ 0,៤0/0,២0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ 0,១0 ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

## ស្រុកពោធិ៍រៀង

អចលនទ្រព្យទាំងឡាយដែលស្ថិតនៅស្រុកពោធិ៍រៀង ត្រូវកំណត់តម្លៃសំណង់ និងដី ក្នុងមួយម៉ែត្រក្រឡា ដូចខាងក្រោម ៖

**ក- សំណង់ ៖** *(ឯកតាគិត ៖ ជាដុល្លារ)*

| ប្រភេទសំណង់ | ដល់ ១០ឆ្នាំ (តម្លៃ/១ម²) | | | លើស ១០ឆ្នាំ (តម្លៃ/១ម²) | | |
|---|---|---|---|---|---|---|
| | សំណង់ឥដ្ឋបេតុង | សំណង់មិនមែនឥដ្ឋបេតុង | ខុនដូ | សំណង់ឥដ្ឋបេតុង | សំណង់មិនមែនឥដ្ឋបេតុង | ខុនដូ |
| ជាន់ក្រោមដី | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៥០ | ១៥០ |
| ជាន់ផ្ទាល់ដី | ១៨០ | ៨០ | ៥០០ | ១៧០ | ៧០ | ៤០០ |
| ជាន់ទី១ | ១៦០ | ៧០ | ៥០០ | ១១០ | ៦០ | ៤០០ |
| ជាន់ទី២ - ទី៥ | ១៣០ | ៦០ | ៥០០ | ៨០ | ៥០ | ៤០០ |
| ជាន់ទី៦ - ទី១០ | ៥៥០ | ៥៥០ | ៥៥០ | ៤៥០ | ៤៥០ | ៤៥០ |
| ចាប់ពីជាន់ទី១១ ឡើងទៅ | ៦៥០ | ៦៥០ | ៦៥០ | ៥៥០ | ៥៥០ | ៥៥០ |

**ខ- ដី ៖**

**ប្រភេទមួយ** ៖ តម្លៃ ៥ដុល្លារ ដីលំនៅដ្ឋាន/០,៧០ដុល្លារ ដីស្រែ-ចំការ ក្នុង១ម៉ែត្រក្រឡា ៖ ដីស្ថិតនៅផ្លូវបេ

- សងខាងកំណាត់ផ្លូវទៅសាលាស្រុក ចាប់ពីផ្លូវជាតិលេខ៨ ដល់សាលាស្រុក
- សងខាងកំណាត់ផ្លូវទៅសាលាស្រុក ចាប់ពីមាត់ទន្លេ ដល់សាលាស្រុក

**ប្រភេទពីរ** ៖ ដីក្រៅពីការកំណត់ក្នុងប្រភេទខាងលើ (ដីលំនៅដ្ឋានដីស្រែ-ចំការ)

១- ឃុំពោធិ៍រៀង មាន ០៤ភូមិ គឺ ៖ ភូមិពោធិ៍រៀងខាងជើង ភូមិពោធិ៍រៀងខាងត្បូង ភូមិវាលព្រៅ និងភូមិយាយសល់
- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

២- ឃុំព្រែកអន្ទះ មាន ០៧ភូមិ គឺ ៖ ភូមិព្រែកអន្ទះ ភូមិផ្តៅ ភូមិច្រាំងទទឹង ភូមិតាម៉ោ ភូមិតាមែង ភូមិអង្គរយស និងភូមិថ្មី
- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៣- ឃុំជ្រៃ មាន ០៥ភូមិ គឺ ៖ ភូមិជ្រៃលើ ភូមិជ្រៃក្រោម ភូមិអន្លង់ត្រា ភូមិបាក់ដោក និងភូមិពាមស្តី
- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៤- ឃុំព្រែកខ្លោង មាន ០៥ភូមិ គឺ ៖ ភូមិស្វាយ ភូមិកំពង់ក្រមួន ភូមិជ្រាវ ភូមិពពីស និងភូមិព្រែកខ្លោង
- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៥- ឃុំតាកោ មាន ០៨ភូមិ គឺ ÷ ភូមិកុកត្រុំ "ក" ភូមិកុកត្រុំ "ខ" ភូមិខ្នយ ភូមិក្អយ ភូមិស្តរដាច ភូមិត្នោតទ្រេត ភូមិតាកោ និងភូមិភក្តនេស្យ

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៦- ឃុំកំពង់ឬស្សី មាន ០៦ភូមិ គឺ ÷ ភូមិល្អា ភូមិព្រៃមាស ភូមិត្នោត ភូមិល្វា ភូមិកំពង់ឬស្សី និងភូមិជ្រៃគ្រហ៊ឹម

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៧- ឃុំព្រៃកគាសរ មាន ០៤ភូមិ គឺ ÷ ភូមិតាព្រះ ភូមិព្រៃកឈ្មោះ ភូមិព្រៃកគាសរ និងភូមិព្រៃកក្រូច

- តម្លៃ ០,៦០/០,៣០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវឃុំ
- តម្លៃ ០,៤០/០,២០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ០,១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

តទៅរាជកិច្ចលេខ ៨៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៣៨ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការចុះបញ្ជីពន្ធដារ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានពន្ធដារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ១.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់វិធាននិងនីតិវិធីនៃការចុះបញ្ជីពន្ធដារ ដោយអនុលោមតាមមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ២.- គោលបំណង**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រងទិន្នន័យសហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ឱ្យបានកាន់តែប្រសើរឡើង
- ពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែមានលក្ខណៈល្អប្រសើរ
- ពង្រឹងការគាំទ្រដល់ការគ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធ ឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

**ប្រការ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តការចុះបញ្ជីពន្ធដារ ចំពោះនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះបច្ចេកសព្ទត្រូវបានកំណត់និយមន័យដូចតទៅ÷

- "**ការចុះបញ្ជីពន្ធដារ**" សំដៅដល់ការចុះបញ្ជីតាមរបបពិត (ស្វ័យប្រកាស) និងរបបម៉ៅការ នៅរដ្ឋបាលសារពើពន្ធចំពោះបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។
- "**សកម្មភាពសេដ្ឋកិច្ច**" សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើអាជីវកម្ម ឬសកម្មភាព ជានិច្ចកាលជាប់បន្ត ឬម្តងម្កាល ដើម្បីរក ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

**ប្រការ៥.- កាតព្វកិច្ចនៃការចុះបញ្ជីពន្ធដារ**

សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ។

សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីការផ្លាស់ប្តូរ អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស ឬការផ្ទេរ។

ចំពោះការបញ្ឈប់ ឬបិទសកម្មភាពអាជីវកម្ម សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬ

បុគ្គលទាំងឡាយ ត្រូវដាក់ពាក្យស្នើសុំជម្រះបញ្ជីមករដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីរដ្ឋបាលសារពើពន្ធធ្វើសវនកម្ម មុននឹងចេញលិខិតបញ្ជាក់ស្ថានភាពសារពើពន្ធជូនជាផ្លូវការ។

**ប្រការ៦.- ការស្នើសុំចុះបញ្ជីពន្ធដារ**

សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារត្រូវធ្វើការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក ( E-registration ) ដែលមាននៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។

ការស្នើសុំចុះបញ្ជីពន្ធដារត្រូវបង់ថ្លៃសេវាចុះបញ្ជី ចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ក្នុងតម្លៃ ៤០០.០០០ រៀល (បួនរយពាន់រៀល) សម្រាប់អ្នកជាប់ពន្ធតាមរបបពិត (ស្វ័យប្រកាស )។ សម្រាប់ការចុះបញ្ជីពន្ធដារតាមរបបម៉ៅការ ត្រូវបង់ថ្លៃសេវាចុះបញ្ជី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ក្នុងតម្លៃ ២០.០០០ រៀល (ម្ភៃពាន់រៀល)។

**ប្រការ៧.- រយៈពេលនៃការចុះបញ្ជីពន្ធដារ**

- ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិក ( E-registration ) ក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ អាចនឹងចំណាយរយៈពេលពី ១ថ្ងៃ ទៅ ៧ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារដោយរដ្ឋបាលសារពើពន្ធ។
- ចំពោះការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ តាមរយៈការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារអាចនឹងចំណាយរយៈពេលពី ៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយរដ្ឋបាលសារពើពន្ធ សម្រាប់ផ្តល់ភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។

**ប្រការ៨.- លក្ខខណ្ឌនៃការចុះបញ្ជីពន្ធដារ**

- **ការចុះបញ្ជីតាមរបបពិត (របបស្វ័យប្រកាស)**

ក្នុងការស្នើសុំចុះបញ្ជីពន្ធដារតាមរបបពិត (ស្វ័យប្រកាស) ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ឬប្រធានអង្គការ ត្រូវមកថតរូប ស្កែន (Scan) ម្រាមដៃផ្ទាល់នៅរដ្ឋបាលសារពើពន្ធ និងត្រូវបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ហើយភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ដើម្បីឱ្យមន្ត្រីពន្ធដារទទួលបន្ទុកបញ្ជាក់ពីការថតចម្លងចេញពីច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់ពីក្រសួង ស្ថាប័នសាមី ដូចខាងក្រោម÷

ក. ចំពោះ សហគ្រាសឯកបុគ្គល និងសហគ្រាសនីតិបុគ្គល

១. ឯកសារចុះបញ្ជីចេញដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ

- លិខិតបញ្ជាក់ការចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ
- លក្ខន្តិកៈក្រុមហ៊ុន សម្រាប់នីតិបុគ្គល
- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ។

២. ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន និងបណ្ណាធិការ

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥ × ៤៥ មីលីម៉ែត្រ ចំនួន ១សន្លឹក របស់អភិបាល ម្ចាស់ភាគហ៊ុន បណ្ណាធិការ អ្នកតំណាង ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល។

៣. ឯកសារបញ្ជាក់ទីតាំងទីចាត់ការសហគ្រាស អាជីវកម្មគោលដើម សាខាសហគ្រាស និងឃ្លាំង

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ។

៤. ឯកសារផ្សេងៗ

- វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)
- អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)។

ខ. ចំពោះអង្គការនានា

១. លិខិតអនុញ្ញាតចេញដោយ ក្រសួង ស្ថាប័ន មានសមត្ថកិច្ច

២. លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច

៣. ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានអង្គការ

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

៤. ឯកសារបញ្ជាក់ទីតាំងអង្គការ

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ។

- **ការចុះបញ្ជីតាមរបបម៉ៅការ**

ក្នុងការស្នើសុំចុះបញ្ជីពន្ធដារតាមរបបម៉ៅការ ម្ចាស់អាជីវកម្មដ្ឋាន ត្រូវបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ហើយភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ដើម្បីឱ្យមន្ត្រីពន្ធដារទទួលបន្ទុកបញ្ជាក់ពីការថតចម្លងចេញពីច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់ពីក្រសួង ស្ថាប័នសាមី ឬស្ថាប័នមានសមត្ថកិច្ច ដូចខាងក្រោម÷

១. លិខិតអនុញ្ញាតចេញដោយ ក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)

២. អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)

៣. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

UK

៤. ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំង

៥. លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

៦. រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥ × ៤៥ មីលីម៉ែត្រ ចំនួន ២សន្លឹក ដោយមានការសរសេរឈ្មោះ និងចុះហត្ថលេខាលើខ្នងរូបថត។

**ប្រការ៩.- ការស្នើសុំបញ្ជាក់សាខាសហគ្រាស**

សហគ្រាសដែលបានចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ហើយបានបង្កើតសាខារបស់ខ្លួន ត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់សាខាសហគ្រាសដោយផ្ទាល់ នៅរដ្ឋបាលសារពើពន្ធដោយផ្ទាល់តាមរយៈការបំពេញពាក្យស្នើសុំលិខិតបញ្ជាក់សាខា ឬតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ចំពោះរយៈពេលនៃការបញ្ជាក់សាខាគឺដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ។

រាល់ការស្នើសុំបញ្ជាក់សាខាសហគ្រាស ត្រូវភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ដើម្បីឱ្យមន្ត្រីពន្ធដារទទួលបន្ទុកបញ្ជាក់ពីការថតចម្លងចេញពីច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់ពីក្រសួង ស្ថាប័នសាមី ដូចខាងក្រោម៖

១. លិខិតទទួលចុះបញ្ជីនូវការបង្កើតសាខាសហគ្រាស របស់ក្រសួងពាណិជ្ជកម្ម ឬក្រសួងស្ថាប័នពាក់ព័ន្ធ

២. ឯកសារបញ្ជាក់ទីតាំងសហគ្រាស

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ។

**ប្រការ១០.- ការបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ**

រដ្ឋបាលសារពើពន្ធ ត្រូវចេញលិខិតបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ ដោយបញ្ជាក់កាលបរិច្ឆេទទទួលសំណុំឯកសារបន្ទាប់ពីបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ៨ ឬប្រការ៩ នៃប្រកាសនេះ។

**ប្រការ១១.- សិទ្ធិរបស់រដ្ឋបាលសារពើពន្ធក្នុងការចុះបញ្ជីអ្នកជាប់ពន្ធ**

អនុលោមតាមមាត្រា ១០៣ នៃច្បាប់ស្ដីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះសហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី តែពុំបានមកចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី។

**ប្រការ១២.- សិទ្ធិរបស់រដ្ឋបាលសារពើពន្ធក្នុងការបដិសេធការចុះបញ្ជីពន្ធដារ**

រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធការចុះបញ្ជីពន្ធដារ ចំពោះសហគ្រាសដែល ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន និងអ្នកតំណាង មានជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសហគ្រាសដទៃដែលមានជំពាក់បំណុលពន្ធ។ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីបាន លុះត្រាតែមានការទូទាត់បំណុលពន្ធជាមុនសិន ឬមានកិច្ចសន្យាធានាសងបំណុលពន្ធ។

**ប្រការ១៣.- សិទ្ធិរបស់អ្នកជាប់ពន្ធក្នុងការតវ៉ាសេចក្តីសម្រេចរដ្ឋបាលសារពើពន្ធ**

ក្នុងករណីរដ្ឋបាលសារពើពន្ធបដិសេធការចុះបញ្ជី អ្នកជាប់ពន្ធមានសិទ្ធិដាក់បណ្តឹងតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការពិនិត្យឡើងវិញនូវការសម្រេចកន្លងមក។ ក្នុងករណីអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធអាចប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១៤.- ការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជី**

ចំពោះសហគ្រាសដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដាររបស់ខ្លួនតាមការជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។ បន្ទាប់ពីបានធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដាររួច រដ្ឋបាលសារពើពន្ធត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារថ្មី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជីពន្ធដារ ត្រូវបង់ថ្លៃសេវាចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារថ្មី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ នៅរដ្ឋបាលសារពើពន្ធ ក្នុងតម្លៃ ២០០.០០០ រៀល (ពីររយពាន់រៀល) សម្រាប់អ្នកជាប់ពន្ធតាមរបបពិត (ស្វ័យប្រកាស)។ សម្រាប់ការចុះបញ្ជីពន្ធដារតាមរបបម៉ៅការ ត្រូវបង់ថ្លៃសេវាចុះបញ្ជី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ នៅរដ្ឋបាលសារពើពន្ធ ក្នុងតម្លៃ ១០.០០០ រៀល(ដប់ពាន់រៀល)។

**ប្រការ១៥.- ទោសទណ្ឌ**

ការមិនបានចុះបញ្ជីពន្ធដារ ឬការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី ត្រូវរងទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ១៦.- និរាករណ៍**

ប្រកាសលេខ ១០០៤ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែប្រែបំពេញបន្ថែមឯកសារក្នុងទម្រង់បែបបទសម្រាប់ការចុះបញ្ជីពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ វិច្ឆិកា ឆ្នាំ២០១៤

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ០៤៣ [illegible]

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែ សម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ២១៩៤/១៤ គ.វ.ក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ីលសារាំង (ខេមបូឌា) ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ីលសារាំង (ខេមបូឌា) (SILSARANG (CAMBODIA) CO., LTD.) តំណាងដោយ លោក LEE WOONGHEE សញ្ជាតិកូរ៉េ អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 7132303 ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ មានអាសយដ្ឋានបច្ចុប្បន្ន៖ 1110dong, 703ho Eunvit Maeul, 11 Danji Apt., Hwajeong, 1-dong, Deogyyang-gu, Goyang-si, Gyeonggi-do, Seoul, Korea. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| អំបោះ | ១៣១១ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ៖** *" រោងចក្រខារអំបោះគ្រប់ប្រភេទ សម្រាប់ផ្គត់ផ្គង់បម្រើឲ្យឧស្សាហកម្ម នាំចេញ ស៊ីលសារ៉ាំង (ខេមបូឌា) "*

**ទីតាំងរោងចក្រ៖** *" ផ្លូវអន្លង់គង ភូមិអន្លង់គង សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងគម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋាន ឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃយ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ។

ខ.ម្ចាស់រោងចក្រ បានផ្តល់ជូនក្រសួងត្រឹមត្រូវ និងបានទៀងទាត់នូវនិទ្ទន័យ របាយការណ៍ផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់។

គ.ម្ចាស់រោងចក្រ បានបង់កម្រៃកម្មសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែង សមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំ អំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ០៨៤៤ [illegible]

# ប្រកាស
# ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ១៨២៨/១៤ គ.វ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំ របស់ក្រុមហ៊ុន ភើហ្វម វែល ហូលឌីង (ខេមបូឌា) លីមីធីត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ភើហ្វម វែល ហូលឌីង (ខេមបូឌា) លីមីធីត (PERFORM WELL HOLDINGS (CAMBODIA) LIMITED.) តំណាងដោយ លោក WANG, LIFENG សញ្ជាតិចិន [illegible] កាន់លិខិតឆ្លងដែនលេខ E25393933 ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ មានអាសយដ្ឋាន [illegible] Jiangsu, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ផ្លាកឈ្មោះរោងចក្រ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ គើហ្វម វែល ហ្វូលឌីង (ខេមបូឌា) លីមីធីត "*

**ទីតាំងរោងចក្រ៖** *" អាគារលេខ ១៦៨ ផ្លូវលំ ភូមិត្រពាំងពើក ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋាន ឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្ដីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្ដីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្ដីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃយ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ។

ខ.ម្ចាស់រោងចក្របានផ្តល់ជូនក្រសួងត្រឹមត្រូវ និងបានទៀងទាត់នូវទិន្នន័យ របាយការណ៍ផលិតកម្ម ប្រចាំ ខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់។

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាកម្មវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែង សមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណ នៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពី ករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការ ប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ៤៥៩ MIH / 2014

# ប្រកាស
## ស្តីពី
## ឯកសណ្ឋានមន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**ប្រការ១ ៖** ប្រកាសនេះមានគោលបំណងបង្កើត និងកំណត់នូវឯកសណ្ឋានមន្ត្រីរាជការ សម្រាប់ប្រើប្រាស់ក្នុងការបំពេញការងារជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

### ជំពូកទី២
### ឯកសណ្ឋាន

**ប្រការ២ ៖** ឯកសណ្ឋានមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានកំណត់ជា ២(ពីរ)ថ្នាក់ដូចខាងក្រោម៖

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

១- ថ្នាក់អនុប្រធាននាយកដ្ឋានឡើង

ក- ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌ផ្ទៃមេឃ កបើក ថ្នេរឌុប ប៉ុលស្មាសងខាង សម្រុងជើងអាវត្រង់ស្មើ ផែកខាងក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២០ស.ម ហើយមានហោប៉ៅចំនួនពីរខាងលើដេរបត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍ និងឡេវជ័រពណ៌ដូចអាវ
- ខោជើងវែងពណ៌ខៀវទឹកប៊ិចចាស់ ដេរថ្នេរបង្កប់ ចង្កេះត ដឹបក្លីខាងមុខពីរ មានហោប៉ៅចំនួនបី ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ចោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ និងខ្សែក្រវ៉ាត់ពណ៌ខ្មៅ។

ខ- ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ខៀវទឹកប៊ិចចាស់ ឬសំពត់ហ្ស៊ីបពណ៌ខៀវទឹកប៊ិចចាស់សម្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ និងខ្សែក្រវ៉ាត់ពណ៌ខ្មៅ។

រូបគំរូឯកសណ្ឋាន មានដូចនៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

២- ថ្នាក់ប្រធានការិយាល័យចុះ

ក- ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌ផ្ទៃមេឃ កឌុប ថ្នេរឌុប ប៉ុលស្មាសងខាង សម្រុងជើងអាវត្រង់ស្មើ ផែកខាងក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២០ស.ម. ហើយមានហោប៉ៅខាងលើចំនួនពីរដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ និងឡេវជ័រពណ៌ដូចអាវ
- ខោជើងវែងពណ៌ខៀវទឹកប៊ិចចាស់ ដេរថ្នេរបង្កប់ ចង្កេះត ដឹបក្លីខាងមុខពីរ មានហោប៉ៅចំនួនបី ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ និងខ្សែក្រវ៉ាត់ពណ៌ខ្មៅ។

ខ- ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ខៀវទឹកប៊ិចចាស់ ឬសំពត់ហ្ស៊ីបពណ៌ខៀវទឹកប៊ិចចាស់សម្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ និងខ្សែក្រវ៉ាត់ពណ៌ខ្មៅ។

រូបគំរូឯកសណ្ឋានមានដូចនៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

## ជំពូកទី៣
## សញ្ញាសម្គាល់

**ប្រការ៣** ៖ ឯកសណ្ឋានសញ្ញាពាក់នៅលើដៃអាវខាងស្តាំ ជាសញ្ញាក្រសួងឧស្សាហកម្ម និងសិប្បកម្ម ធ្វើអំពីក្រណាត់ក្រាស់រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨ស.ម.។

**ប្រការ៤** ៖ ស្លាកសម្គាល់ឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំ មានរាងចតុកោណកែង ដែលមានបណ្តោយប្រវែង៩,៥ស.ម. ទទឹង២,០ស.ម. ដែលសរសេរអក្សរពណ៌ទឹកមាស និងពាសដោយជ័រវើងថ្លាមានផ្ទៃពណ៌ខៀវទឹកប៊ិច និងមានខ្សែបន្ទាត់ស្តើងពណ៌មាស ព័ទ្ធជុំវិញ ដែលមានទំហំ០,១៥ស.ម.។ ប៉ែកខាងស្តាំដៃនៃស្លាកឈ្មោះមានសញ្ញាក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយប៉ែកខាងឆ្វេង មានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមានអត្តលេខរបស់មន្ត្រីរាជការ។

**ប្រការ៥** ៖ ឯកសណ្ឋានដូចមានចែងក្នុងប្រការខាងលើនេះ ត្រូវបានប្រើប្រាស់ទាំងនៅថ្នាក់រដ្ឋបាលកណ្តាល និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត សម្រាប់ពេលបំពេញបេសកម្មជូនក្រសួង ឬ នៅក្នុងកម្មវិធីផ្សេងៗទៀតតាមការតម្រូវ លើកលែងតែមន្ត្រីរាជការនៃអង្គភាពដែលមានឯកសណ្ឋានកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ៦** ៖ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧** ៖ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៧
  "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

**នៃប្រកាសលេខ ៖ ..៥៥៩...MIH/2014 ចុះថ្ងៃទី ២៧.. ខែ តុលា... ឆ្នាំ២០១៤**
**ស្តីពី ឯកសណ្ឋានមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានឡើង**



# ឧបសម្ព័ន្ធទី២

**នៃប្រកាសលេខ ៖ ៥៥៩...MIH/2014 ចុះថ្ងៃទី ២៧ ខែ តុលា... ឆ្នាំ២០១៤**
**ស្តីពី ឯកសណ្ឋានមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចាប់ពីថ្នាក់ប្រធានការិយាល័យចុះ**

